រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

## សារាចរណែនាំលេខ : ០១ សរណន
## ស្ដីពីការរៀបចំទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ១៩៩៦
## ខួបលើកទី ៨៦ នៅគ្រប់ក្រសួង ស្ថាប័ន និង ខេត្ត—ក្រុង
## ទូទាំងព្រះរាជាណាចក្រកម្ពុជា

* * *

– ដោយយល់ឃើញថា ក្រោមព្រះរាជកិច្ចដឹកនាំ និង មួយដ៏ត្រជាក់នៃព្រះមហាក្សត្រព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** និង សម្ដេចព្រះ រាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** នៃកម្ពុជា នារីកម្ពុជាគ្រប់មជ្ឈដ្ឋានរួបរួមគ្នាប្រារព្ធទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ ១៩៩៦ ដែលជាខួប លើកទី ៨៦ នៅថ្ងៃទី ៦–៧– ខែ មីនា ឆ្នាំ ១៩៩៦ ខាងមុខនេះ ។

– ដោយមានបំណងរួម ក្នុងការលើកស្ទួយសិទ្ធិនារី តាមសកម្មភាពជាក់ស្ដែងឆ្ពោះទៅរកទិសដៅសំខាន់ គឺ ÷

ប្រមូលកំលាំងនារីខ្មែរ រួមសាមគ្គីជុំវិញព្រះរាជបល្ល័ង្ក ការពារសិទ្ធិនារីក្នុងគ្រួសារ និងក្នុងសង្គមជាតិ បង្កើនតួនាទីក្នុងការកសាង និង អភិវឌ្ឍន៍ជាតិក្នុងឆ្នាំ ១៩៩៦ និងតទៅអនាគត ។

ដើម្បីអបអរសាទរបុណ្យទិវានារីអន្តរជាតិ ៨ មីនា រាជរដ្ឋាភិបាល សូមធ្វើការណែនាំចំពោះគ្រប់ ក្រសួង ស្ថាប័ន និង អាជ្ញាធរខេត្ត–ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវយកចិត្តទុកដាក់ក្នុងការផ្ដល់លទ្ធភាព និងជួយឧបត្ថម្ភដល់តំណាងការពារផលប្រយោជន៍នារីរបស់ក្រសួង ស្ថាប័នសាមី អោយចូលរួមធ្វើសកម្មភាព និង តាំងពិព័រណ៍នៅកន្លែងប្រមូលផ្ដុំសំរាប់ប្រារព្ធពិធី ០៨ មីនា ដែលរៀបចំដោយក្រសួងកិច្ចការនារី និង ជួយឧបត្ថម្ភប្រធានមន្ទីរកិច្ចការនារីខេត្ត–ក្រុង ក្នុងការប្រារព្ធពិធីបុណ្យទិវានារីអន្តរជាតិ ៨ មីនា នៅតាមខេត្ត–ក្រុង នីមួយ ។ នាពេលខាងមុខនេះ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ត្រូវចាត់ចែងផ្សព្វផ្សាយ និង អនុវត្តអោយទទួលបានលទ្ធផលល្អប្រសើរ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# III - ការងារបណ្ដាក្រសួង

## ១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៤៨ ប្រក.សហវ.ហ**

**ស្ដីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ**

* * *

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា